ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៧៩០ សរាណន. កសក

# សារាចរណែនាំ

## ស្តីពី

## ការសង្គ្រោះ និងបង្ការទប់ស្កាត់ជំងឺសត្វដោយសារគ្រោះរាំងស្ងួត

នៅប៉ុន្មានសប្តាហ៍កន្លងមកនេះ មានការកើនឡើងកម្ដៅខុសប្រក្រតីបណ្ដាលឱ្យប្រភពទឹករីងស្ងួត ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រភពចំណីសត្វ និងខ្វះទឹកសម្រាប់សត្វពាហនៈនិងសត្វចិញ្ចឹមដទៃទៀត ដែលបណ្ដាលឱ្យសត្វទាំងនោះប្រឈមហានីភ័យសុខភាព ស្ត្រេស បាត់បង់សារធាតុចិញ្ចឹម និងខ្វះជាតិទឹកក្នុងសារពាង្គកាយ ព្រមទាំងងាយរងគ្រោះដល់ការរាតត្បាតនៃជំងឺនានា។ ថ្មីៗនេះ សត្វពាហនៈនិងសត្វចិញ្ចឹមរបស់ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាលមួយចំនួនបាននិងកំពុងប្រឈមនឹងការខ្វះចំណី ទឹក និងការរាតត្បាតដោយជំងឺនានា ហើយបានស្លាប់ជាបន្តបន្ទាប់។ ស្ថិតក្នុងស្ថានភាពចំពោះមុខនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល មន្ទីរកសិកម្ម រាជធានី-ខេត្ត អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ រួមសហការអនុវត្តវិធានការសង្គ្រោះសត្វ និងគ្រប់គ្រងហានីភ័យសុខភាពសត្វដូចខាងក្រោម៖

១- កំណត់តំបន់ដែលប្រឈមហានីភ័យ និងចាត់ក្រុមអន្តរាគមន៍ជួយសង្គ្រោះសត្វ ជាប្រចាំនិងទាន់ពេលវេលា។

២- ធ្វើការណែនាំអប់រំដល់ម្ចាស់សត្វអំពីវិធីរៀបចំចំណីសម្រាប់បម្រុងនិងថែទាំសត្វ រក្សាសត្វក្នុងទ្រុងឬក្រោល ឬប្រមូលផ្តុំនៅទីសុវត្ថិភាព។

៣- ផ្តល់កិច្ចអន្តរាគមន៍ចំណីសត្វ ទឹក និងថ្នាំព្យាបាល ដើម្បីសង្គ្រោះអាយុជីវិតសត្វនៅតំបន់ដែលរងគ្រោះទាំងនោះតាមគ្រប់មធ្យោបាយដែលមាន។

៤- សូមរាយការណ៍ករណីសង្ស័យសត្វឈឺ និងស្លាប់ទៅនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលតាមលេខទូរស័ព្ទ ០១២ ២១៤ ៩៧០ ដើម្បីមានវិធានការអន្តរាគមន៍ទាន់ពេលវេលា។

៥- សូមសហការជាមួយដៃគូអភិវឌ្ឍន៍នានា អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធ ប្រមូលផ្តុំធនធាន មធ្យោបាយ ក្នុងការផ្តល់កិច្ចអន្តរាគមន៍សង្គ្រោះសត្វរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ទទួលបាននូវសារាចរណែនាំនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមយ៉ាងមុតមាំ និងជឿជាក់ថា សមត្ថកិច្ចជំនាញផលិតកម្ម និងបសុព្យាបាល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គការដៃគូអភិវឌ្ឍន៍នានា ផ្តល់កិច្ចសហការ និងអន្តរាគមន៍ជួយសង្គ្រោះសត្វរបស់ប្រជាពលរដ្ឋប្រកបដោយស្មារតីសាមគ្គីភាពនិងទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត

  " ដើម្បីជូនជ្រាប "

- គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់មន្ទីរកសិកម្ម រាជធានី-ខេត្ត

  " ដើម្បីជ្រាបនិងអនុវត្ត "

- ឯកសារ កាលប្បវត្តិ